# របាយការណ៍ជាលាយលក្ខណ៍អក្សរសម្រាប់សិស្សដែលរៀនភាសាអង់គ្លេសជាភាសាបន្ថែម ឬគ្រាមភាសា K-10

## ព័ត៌មានសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ

សូមជម្រាបជូនឪពុកម្ដាយ និងអ្នកថែទាំជាទីរាប់អាន

អ្នកទទួលបានរបាយការណ៍ជាលាយលក្ខណ៍អក្សរចំនួនពីរច្បាប់ពីសាលារៀនរបស់កូនអ្នកជារៀងរាល់ឆ្នាំ។ របាយការណ៍ទាំងនេះនឹងជួយអ្នកឱ្យយល់ដឹងពីរបៀបដែលកូនរបស់អ្នកកំពុងរីកចម្រើន និងរបៀបដែលសាលារៀនរបស់អ្នកកំពុងគាំទ្រដល់ការរៀនសូត្ររបស់កូនអ្នក។ របាយការណ៍នីមួយៗ នឹងបង្ហាញពីការរីកចម្រើនរបស់កូនអ្នកលើគ្រប់មុខវិជ្ជា។

### របាយការណ៍សម្រាប់សិស្សដែលរៀនភាសាអង់គ្លេសជាភាសាបន្ថែម ឬគ្រាមភាសា (English as an additional language or dialect (EAL/D))

ប្រសិនបើកូនរបស់អ្នកកំពុងរៀនភាសាអង់គ្លេសជាភាសាបន្ថែម ឬគ្រាមភាសា (EAL/D) របាយការណ៍នោះនឹងពន្យល់ពីរបៀបដែលការអភិវឌ្ឍន៍ភាសាអង់គ្លេសរបស់ពួកគេត្រូវបានគាំទ្រ និងការរីកចម្រើនរបស់កូនអ្នកក្នុងការរៀនភាសាអង់គ្លេស។ សម្រាប់សិស្សថ្នាក់ទី 1 និងថ្នាក់ខ្ពស់ជាងនេះ របាយការណ៍នឹងរួមបញ្ចូលដំណាក់កាលបច្ចុប្បន្ននៃជំនាញភាសាអង់គ្លេសរបស់ពួកគេផងដែរ។ ដំណាក់កាលទាំងនេះគឺ កំពុងចាប់ផ្ដើម កំពុងលេចធ្លោ កំពុងអភិវឌ្ឍ ឬកំពុងដាក់បង្រួមចូលគ្នា។ សូមមើលទំព័រម្ខាងទៀតសម្រាប់ការពិពណ៌នាអំពីដំណាក់កាលទាំងនេះ។

### របាយការណ៍សម្រាប់សិស្សដែលទើបមកដល់ថ្មីៗ (EAL/D)

ប្រសិនបើកូនរបស់អ្នកស្ថិតនៅក្នុងកម្មវិធី EAL/D ហើយបានចូលរៀននៅសាលាអូស្ត្រាលីចំនួនបួនត្រីមាស ឬតិចជាងនេះ របាយការណ៍ជាលាយលក្ខណ៍អក្សររបស់កូនអ្នកអាចរួមបញ្ចូល មតិយោបល់អំពីការរីកចម្រើនរបស់ពួកគេក្នុងមុខវិជ្ជាដែលពួកគេកំពុងរៀនជាជាងការផ្ដល់ពិន្ទុ។

### របាយការណ៍សម្រាប់សិស្ស EAL/D ដែលទើបមកដល់ថ្មីៗនៅក្នុងមជ្ឈមណ្ឌលភាសាអង់គ្លេសសកម្ម ឬវិទ្យាល័យភាសាអង់គ្លេសសកម្ម

ប្រសិនបើកូនរបស់អ្នកបានចុះឈ្មោះចូលរៀននៅមជ្ឈមណ្ឌលភាសាអង់គ្លេសសកម្ម ឬវិទ្យាល័យភាសាអង់គ្លេសសកម្ម អ្នកនឹងទទួលបានរបាយការណ៍ជាលាយលក្ខណ៍អក្សរមួយ អំពីការរីកច្រើនរបស់ពួកគេក្នុងការរៀនភាសាអង់គ្លេស។ លើសពីនេះ របាយការណ៍នឹងបង្ហាញពីការរីកចម្រើនលើមុខវិជ្ជាទាំងអស់ដែលបានសិក្សាក្នុងការត្រៀមបម្រុងសម្រាប់វិទ្យាល័យ។

| ដំណាក់កាលជំនាញភាសាអង់គ្លេស | |
|---|---|
| **កំពុងចាប់ផ្ដើម** | សិស្សនៅដំណាក់កាលកំពុងចាប់ផ្ដើម កំពុងចាប់ផ្ដើមរៀនភាសាអង់គ្លេស។ ពួកគេអាចនិយាយបានមួយ ឬច្រើនភាសាក្រៅពីភាសាអង់គ្លេស ហើយអាចមានកម្រិតអក្ខរកម្មសរសេរស្របទៅតាមអាយុក្នុងភាសាដំបូងរបស់ពួកគេ។ សិស្សទាំងនេះកំពុងចាប់ផ្ដើមចូលរួមក្នុងកិច្ចការភាសាសាមញ្ញៗនៃកម្មវិធីសិក្សា។ |
| **កំពុងលេចធ្លោ** | សិស្សនៅដំណាក់កាលកំពុងលេចធ្លោ មានការលូតលាស់ចំណេះដឹងអំពីភាសាអង់គ្លេស។ សិស្សទាំងនេះអាចនិយាយបានមួយ ឬច្រើនភាសា រួមទាំងភាសាអង់គ្លេសជាមូលដ្ឋាន ហើយមានការលូតលាស់ចំណេះដឹងអំពីការសរសេរជាភាសាអង់គ្លេស។ សិស្សទាំងនេះអាចចូលរួមក្នុងសកម្មភាពក្នុងថ្នាក់រៀន និងចូលរួមជាមួយការរៀនសូត្រ នៅពេលបានផ្ដល់ការបង្រៀនភាសាសមរម្យ និងពេលវេលាបន្ថែមដើម្បីបំពេញសកម្មភាពក្នុងថ្នាក់រៀន។ |
| **កំពុងអភិវឌ្ឍ** | សិស្សនៅដំណាក់កាលអភិវឌ្ឍ អាចនិយាយបានមួយ ឬច្រើនភាសា រួមទាំងភាសាអង់គ្លេសដែលអាចប្រើការបាន ហើយមានចំណេះដឹងអំពីការសរសេរជាភាសាអង់គ្លេស។ សិស្សទាំងនេះគឺជាអ្នកចូលរួមសកម្មក្នុងថ្នាក់រៀន និងទម្លាប់របស់សាលា ហើយអាចចូលរួមក្នុងកិច្ចការរៀនសូត្រដោយមានភាពជោគជ័យកាន់តែខ្លាំង។ ភាសាដំបូងរបស់ពួកគេបន្តគាំទ្រដ៏មានតម្លៃ ខណៈពេលដែលពួកគេកំពុងអភិវឌ្ឍការគ្រប់គ្រងលើវេយ្យាករណ៍ភាសាអង់គ្លេស និងការកសាងវាក្យសព្ទរបស់ពួកគេ។ |
| **កំពុងដាក់បង្រួមចូលគ្នា** | សិស្សនៅដំណាក់កាលដាក់បង្រួមចូលគ្នា អាចនិយាយបានមួយ ឬច្រើនភាសា រួមទាំងភាសាអង់គ្លេស ហើយមានចំណេះដឹងច្បាស់លាស់អំពីការសរសេរជាភាសាអង់គ្លេស។។ សិស្សទាំងនេះគឺជាអ្នកចូលរួមដោយឯករាជ្យក្នុងថ្នាក់រៀន និងទម្លាប់របស់សាលា ហើយមានសមត្ថភាពក្នុងការប្រើភាសាអង់គ្លេសដើម្បីចូលរួមក្នុងការរៀនសូត្រដោយមានភាពជោគជ័យទូទៅ។ ពួកគេយល់ និងបង្កើតអត្ថបទនិយាយ និងសរសេរសម្រាប់គោលបំណងជាក់លាក់មួយចំនួន ប៉ុន្តែនៅតែត្រូវការការបង្រៀនភាសាដែលផ្ដោត និងយុទ្ធសាស្ត្រគាំទ្រអ្នកសិក្សា EAL/D នៅពេលដែលភាសាសិក្សានៃមុខវិជ្ជាកើនឡើង។ |

## សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែម សូមទាក់ទងសាលារៀន។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយអ្នកក្នុងការទាក់ទងមកសាលារៀន សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ លេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ អ្នកបកប្រែផ្ទាល់មាត់នឹងទូរសព្ទទៅសាលារៀន ហើយនឹងនៅបន្តទំនាក់ទំនងតាមទូរសព្ទដើម្បីជួយក្នុងការសន្ទនារបស់អ្នក។។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។